# ពពួកសត្វជាមិត្តរបស់កសិករ

សហការរៀបចំដោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និងនាយកដ្ឋានដំណាំស្រូវ

បងប្អូនប្រជាកសិករត្រូវចងចាំថា សត្វមានប្រយោជន៍ជាមិត្តម៉ឺនឆ្នាំរបស់កសិករ និងជាកងការពារមិនទារកម្រៃ។ សត្វមានប្រយោជន៍មាន ៣ កង គឺកងទ័ពជើងអាកាស (ពពួកហើរ) កងទ័ពជើងគោក (ពពួកនៅលើដី) និងកងទ័ពជើងទឹក (សត្វក្នុងទឹក) ដែលស្ថិតនៅជាប្រចាំ ការពារស្រូវទាំងយប់ទាំងថ្ងៃ។

លើសពីនេះទៀត នៅគ្រប់ដំណាក់កាលលូតលាស់របស់សត្វចង្រៃមានសត្វមានប្រយោជន៍ស៊ីបំផ្លាញ ។ ប្រសិនបើអាចថែរក្សាការពារពពួកសត្វទាំងនេះបានកសិករអាចរក្សាបាននូវតុល្យភាពជីវសាស្ត្រក្នុងស្រែ ជៀសវាងបានពីការបំផ្លាញធ្ងន់ធ្ងររបស់សត្វចង្រៃ និងអាចរក្សាបាននូវទិន្នផលស្រូវមិនឲ្យបាត់បង់។ ប៉ុន្តែកសិករភាគច្រើនមិនបានយល់អំពីសារប្រយោជន៍នេះហើយបានប្រើប្រាស់ថ្នាំពុលគីមីច្រើនធ្វើឲ្យសត្វមានប្រយោជន៍នៅក្នុងស្រែងាប់អស់ ជាហេតុធ្វើឲ្យពួកគាត់ចាត់វិធានការកាពារស្រូវដោយខ្លួនឯង។

## ១- សត្វពស់ និងទីទុយ

សត្វពស់ និងសត្វស្លាបមួយចំនួនរួមទាំងទីទុយគឺជាសត្វប្រដាប់យ៉ាងសំខាន់ក្នុងការកំចាត់សត្វកណ្តុរដើម្បីការពារស្រូវជូនកសិករ ។



ប្រភេទសត្វពស់ស៊ីកណ្តុរ



សត្វទីទុយស៊ីកណ្តុរ

## សត្វក្នុងទឹក

សត្វនៅក្នុងទឹកស្ទើរទាំងអស់ជាសត្វមានប្រយោជន៍ ដូចជាស្រឹងទឹកគ្រប់ប្រភេទ កន្ធាទូក កន្តេះឡង់ ត្រី និងកង្កែប។ល។ ជាធម្មតាសត្វក្នុងទឹកស៊ីសត្វល្អិតផ្សេងៗដែលធ្លាក់ចូលទៅក្នុងទឹកជាអាហារ ដូច្នេះ សម្រាប់ស្រែមានទឹកច្រើន ឬស្រែមានប្រព័ន្ធស្រោចស្រពត្រឹមត្រូវ មានលក្ខណៈងាយស្រួលក្នុងការគ្រប់គ្រងសត្វចង្រៃបំផ្លាញដំណាំព្រោះយើងអាចជួយធ្វើ



សត្វកន្ធាទូក

អន្តរាគមន៍ដោយពន្លិច ឬគោះដើមស្រូវឲ្យធ្លាក់សត្វល្អិតទៅក្នុងទឹក។



ស្រឹងទឹកជើងវែង



សត្វកន្ទេះឡង់



សត្វកង្កែប



ស្រឹងទឹកតូច



សត្វត្រីក្នុងស្រែ



ស្រឹងទឹកពោះកំប៉ោង